**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ : ៣៧ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការរៀបចំនិងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការប្រកួតប្រជែងកម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០២១/០១៣ ចុះថ្ងៃទី៥ ខែតុលា ឆ្នាំ២០២១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការប្រកួតប្រជែង
- បានឃើញអនុក្រឹត្យលេខ៣៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

## សម្រេច
## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១ ._**

អនុក្រឹត្យនេះកំណត់អំពីការរៀបចំនិងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការប្រកួតប្រជែងកម្ពុជា ដែលសរសេរជាអក្សរកាត់ថា **គ.ប.ក.** ក្នុងគោលបំណងជំរុញនិងលើកកម្ពស់ការអនុវត្តច្បាប់ស្តីពីការប្រកួតប្រជែងប្រកបដោយប្រសិទ្ធភាព និងជួយអ្នកប្រើប្រាស់ឱ្យទទួលបានទំនិញនិងសេវាមានគុណភាពខ្ពស់ ថ្លៃទាប សម្បូរបែប និងមានជម្រើសច្រើន។

## ជំពូកទី២
## សមាសភាព តួនាទី និងភារកិច្ចរបស់ គ.ប.ក.

**មាត្រា២ ._**

**គ.ប.ក.** មានសមាសភាពដូចខាងក្រោម៖

| | |
|---|---|
| - រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម | ប្រធាន |
| - រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម១រូប | អនុប្រធានអចិន្ត្រៃយ៍ |
| - រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី១រូប | អនុប្រធាន |
| - រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ១រូប | អនុប្រធាន |
| - រដ្ឋលេខាធិការក្រសួងមហាផ្ទៃ១រូប | អនុប្រធាន |
| - រដ្ឋលេខាធិការក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងយុត្តិធម៌១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍១រូប | សមាជិក |
| - តំណាងធនាគារជាតិនៃកម្ពុជា១រូប | សមាជិក |
| - អតីតចៅក្រម១រូប | សមាជិក |
| - បុគ្គលមានចំណេះដឹងនិងបទពិសោធផ្នែកច្បាប់២រូប | សមាជិក |
| - បុគ្គលមានចំណេះដឹងនិងបទពិសោធផ្នែកសេដ្ឋកិច្ច២រូប | សមាជិក |
| - អគ្គនាយកនៃអគ្គនាយកដ្ឋានការពារអ្នកប្រើប្រាស់ កិច្ចការប្រកួតប្រជែង និងបង្ក្រាបការក្លែងបន្លំ | សមាជិក។ |

**គ.ប.ក.** អាចស្នើសុំសមាជិកបន្ថែមតាមការចាំបាច់។

សមាសភាពជាក់ស្តែងរបស់ **គ.ប.ក.** ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល។

**មាត្រា៣ ._**

**គ.ប.ក.** មានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- រៀបចំគោលនយោបាយនិងផែនការយុទ្ធសាស្ត្រដែលទាក់ទងដល់ការប្រកួតប្រជែង
- ផ្តល់យោបល់លើសេចក្តីព្រាងលិខិតបទដ្ឋានគតិយុត្តទាំងឡាយដែលពាក់ព័ន្ធដល់ការប្រកួតប្រជែង ជូនរាជរដ្ឋាភិបាល
- ស្នើសុំរាជរដ្ឋាភិបាលធ្វើការកែសម្រួលឬវិសោធនកម្មលើលិខិតបទដ្ឋានគតិយុត្តជាតិនិងអន្តរជាតិដែល ប៉ះពាល់ដល់ការប្រកួតប្រជែង
- ចេញសេចក្តីសម្រេច ចេញវិធានការផ្អាកឬឃាត់ទុកជាបណ្តោះអាសន្ន និងធ្វើការផាកពិន័យជាប្រាក់ ចំពោះការព្រមព្រៀង ឬសកម្មភាពបំពានច្បាប់ស្តីពីការប្រកួតប្រជែង ព្រមទាំងការរួមបញ្ចូលគ្នានៃធុរកិច្ច ដែលរារាំង រឹតត្បិត ឬបង្ខូចដល់ការប្រកួតប្រជែង
- បង្កើតបែបបទនិងនីតិវិធីនៃការគណនាប្រាក់ផាកពិន័យ
- បង្កើតវិធានទាក់ទងនឹងទំនាស់ផលប្រយោជន៍របស់សមាជិក **គ.ប.ក.**
- រៀបចំលក្ខខណ្ឌនិងនីតិវិធីអំពីការរួមបញ្ចូលគ្នានៃធុរកិច្ច
- រៀបចំលក្ខខណ្ឌនិងនីតិវិធីនៃការផ្តល់ការអនុញ្ញាតចំពោះការព្រមព្រៀងឬសកម្មភាពណាមួយពាក់ព័ន្ធ នឹងការប្រកួតប្រជែង
- រៀបចំលក្ខខណ្ឌនិងនីតិវិធីនៃការផ្តល់ការអនុញ្ញាតជាសមូហភាពចំពោះការព្រមព្រៀងឬសកម្មភាព ណាមួយពាក់ព័ន្ធនឹងការប្រកួតប្រជែង
- រៀបចំលក្ខខណ្ឌនិងនីតិវិធីអំពីគោលការណ៍អនុគ្រោះលើការផាកពិន័យជាប្រាក់
- ធ្វើកិច្ចសហប្រតិបត្តិការជាមួយស្ថាប័នឬបញ្ញត្តិករមានសមត្ថកិច្ចជាតិ រដ្ឋបរទេស និងអន្តរជាតិពាក់ព័ន្ធនឹង ការប្រកួតប្រជែង
- ទទួល ពិនិត្យ និងដោះស្រាយពាក្យបណ្តឹងដែលពាក់ព័ន្ធនឹងការប្រកួតប្រជែងដូចមានចែងក្នុងច្បាប់ ស្តីពីការប្រកួតប្រជែង
- បង្កើតបទប្បញ្ញត្តិនិងវិធានផ្សេងៗទៀត ដែលជាសមត្ថកិច្ចរបស់ **គ.ប.ក.** ពាក់ព័ន្ធនឹងការប្រកួតប្រជែង
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលនាយករដ្ឋមន្ត្រីប្រគល់ជូន។

## ជំពូកទី៣
## ការប្រព្រឹត្តទៅរបស់ គ.ប.ក.

**មាត្រា៤ ._**

ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវចាត់តាំងតំណាងរបស់ខ្លួនឱ្យចូលរួមជាសមាជិក **គ.ប.ក.** បន្ទាប់ពីទទួលបាន សំណើពីរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មនិងជាប្រធាន **គ.ប.ក.**។

សមាជិក **គ.ប.ក.** ដែលជាបុគ្គលឯករាជ្យ ត្រូវជ្រើសរើសដោយរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មតាមនីតិវិធី ច្បាប់។

ឋានៈសមាជិក **គ.ប.ក.** ដែលជាបុគ្គលឯករាជ្យត្រូវសម្រេចដោយប្រមុខរាជរដ្ឋាភិបាលតាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម។

នៅពេលទទួលបានសមាសភាពតំណាងមកពីក្រសួង ស្ថាប័នពាក់ព័ន្ធ និងទទួលបាននូវបេក្ខភាពសមាជិក **គ.ប.ក.** ដែលជាបុគ្គលឯករាជ្យ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មនិងជាប្រធាន **គ.ប.ក.** ត្រូវលើកសំណើជូនរាជរដ្ឋាភិបាលដើម្បីធ្វើការតែងតាំងសមាសភាពនៃ **គ.ប.ក.**។

**មាត្រា៥ ._**

**គ.ប.ក.** ប្រជុំសាមញ្ញយ៉ាងតិច៤(បួន)ដងក្នុងមួយឆ្នាំ។ ក្នុងករណីចាំបាច់ **គ.ប.ក.** អាចប្រជុំជាវិសាមញ្ញតាមការកោះអញ្ជើញរបស់ប្រធាន **គ.ប.ក.**។

ក្នុងករណីដែលប្រធាន **គ.ប.ក.** អវត្តមានប្រធានអាចប្រគល់សិទ្ធិជូនអនុប្រធានអចិន្ត្រៃយ៍ឬអនុប្រធានណាម្នាក់ដឹកនាំប្រជុំជំនួសបាន។

**គ.ប.ក.** សម្រេចតាមសំឡេងភាគច្រើននៃសមាជិក **គ.ប.ក.** ដែលមានវត្តមាន។ ក្នុងករណីសំឡេងឆ្នោតស្មើគ្នា សំឡេងរបស់ប្រធានអង្គប្រជុំមានឧត្តមានុភាព។

**មាត្រា៦ ._**

របៀបរបបការងាររបស់ **គ.ប.ក.** ត្រូវកំណត់ដោយបទបញ្ជាផ្ទៃក្នុង។

**មាត្រា៧ ._**

**គ.ប.ក.** មានសិទ្ធិប្រើរូបសញ្ញានិងត្រារបស់ក្រសួងពាណិជ្ជកម្ម។

**មាត្រា៨ ._**

សមាជិក **គ.ប.ក.** អាចត្រូវបានបញ្ចប់ឬផ្លាស់ប្តូរសមាជិកភាព ក្នុងករណីណាមួយដូចខាងក្រោម៖

ក. តាមសំណើរបស់ប្រធានក្រសួង ស្ថាប័នសាមី។

ខ. ត្រូវបានបោះឆ្នោតដកហូតសមាជិកភាពដោយសំឡេងភាគច្រើន២/៣(ពីរភាគបី)នៃសមាជិក **គ.ប.ក.** ដែលមានវត្តមាន ក្នុងករណីសមាជិករូបនោះអសមត្ថភាពផ្នែកកាយសម្បទាឬបញ្ញាស្មារតី ដែលពុំអាចបំពេញតួនាទីរបស់ខ្លួន ឬមានអាកប្បកិរិយាមិនសក្តិសមជាសមាជិករបស់ **គ.ប.ក.**។

គ. ត្រូវបានផ្តន្ទាទោសពីបទល្មើសដែលពាក់ព័ន្ធនឹងកិច្ចការប្រកួតប្រជែង ឬបទមជ្ឈិម ឬបទឧក្រិដ្ឋណាមួយ។

ឃ. ទទួលមរណភាព។

**មាត្រា៩ ._**

សមាជិក **គ.ប.ក.** ដែលមានទំនាស់ផលប្រយោជន៍ត្រូវដកខ្លួនចេញពីកិច្ចប្រជុំ **គ.ប.ក.**។ ក្នុងករណីសមាជិកមានទំនាស់ផលប្រយោជន៍មិនស្ម័គ្រចិត្តដកខ្លួនចេញពីអង្គប្រជុំ **គ.ប.ក.**ត្រូវបោះឆ្នោតសម្រេចបន្ទាប់ពីសាមីខ្លួនបានការពារខ្លួនចំពោះមុខកិច្ចប្រជុំ។ លក្ខខណ្ឌនៃការដកខ្លួនរបស់សមាជិក **គ.ប.ក.** ត្រូវកំណត់ក្នុងបទបញ្ជាផ្ទៃក្នុង។

**មាត្រា១០ ._**

**គ.ប.ក.** មានអគ្គនាយកដ្ឋានការពារអ្នកប្រើប្រាស់ កិច្ចការប្រកួតប្រជែង និងបង្ក្រាបការក្លែងបន្លំ **ក.ប.ប.** ជាលេខាធិការដ្ឋាន។

អគ្គនាយកនៃអគ្គនាយកដ្ឋានការពារអ្នកប្រើប្រាស់ កិច្ចការប្រកួតប្រជែង និងបង្ក្រាបការក្លែងបន្លំជាប្រធានលេខាធិការដ្ឋាន **គ.ប.ក.**។

តួនាទីនិងភារកិច្ចរបស់លេខាធិការដ្ឋាន **គ.ប.ក.** ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មនិងជាប្រធាន **គ.ប.ក.**។

**មាត្រា១១ .-**

**គ.ប.ក.** អាចបង្កើតគណៈកម្មការលើករណីប្រកួតប្រជែង ក្នុងគោលបំណងពិនិត្យនិងស្រាវជ្រាវលើករណីប្រកួតប្រជែង ដើម្បីស្នើសុំ **គ.ប.ក.** ចេញសេចក្តីសម្រេច ស្របតាមមាត្រា២៨នៃច្បាប់ស្តីពីការប្រកួតប្រជែង។

គណៈកម្មការលើករណីប្រកួតប្រជែង ត្រូវមានសមាជិកយ៉ាងតិច៣(បី)រូប និងច្រើនបំផុត៥(ប្រាំ)រូប ដែលមានសមាសភាពដូចខាងក្រោម៖

- ប្រធានគណៈកម្មការលើករណីប្រកួតប្រជែង
- សមាជិក **គ.ប.ក.** ដែលជាអគ្គនាយកនៃអគ្គនាយកដ្ឋាន **ក.ប.ប.**
- សមាជិក **គ.ប.ក.** ដែលជាបុគ្គលឯករាជ្យ យ៉ាងតិច១(មួយ)រូប។

គណៈកម្មការលើករណីប្រកួតប្រជែងត្រូវធ្វើរបាយការណ៍ស្តីពីលទ្ធផលពិនិត្យនិងស្រាវជ្រាវជូន **គ.ប.ក.**។

## ជំពូកទី៤
## ប្រភពធនធានរបស់គ.ប.ក.

**មាត្រា១២ .-**

ប្រភពធនធាននិងថវិការបស់ **គ.ប.ក.** រួមមាន៖

- **គ.ប.ក.** មានប្រភពធនធានផ្គត់ផ្គង់ដោយថវិកាជាតិដែលជាកញ្ចប់ថវិកាដោយឡែកនៅក្នុងក្របខ័ណ្ឌថវិកាប្រចាំឆ្នាំរបស់ក្រសួងពាណិជ្ជកម្ម
- **គ.ប.ក.** មានសិទ្ធិទទួល គ្រប់គ្រង និងចាត់ចែងប្រើប្រាស់មូលនិធិស្របតាមនីតិវិធីនិងដូចមានកំណត់ក្នុងច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន ដែលបានមកពីប្រភពស្របច្បាប់ហិរញ្ញប្បទានសហប្រតិបត្តិការទាំងក្នុងនិងក្រៅប្រទេស។

ក្រៅពីប្រភពធនធាននិងថវិកាដូចមានចែងក្នុងកថាខណ្ឌទី១ខាងលើ **គ.ប.ក.** ក៏មានប្រភពធនធានផ្សេងទៀតដែលបានមកពីប្រាក់ផាកពិន័យនិងសេវានានា ដែលកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនិងរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម។

**មាត្រា១៣ .-**

លាភការរបស់ **គ.ប.ក.** ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនិងរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម។

## ជំពូកទី៥
## អវសានប្បញ្ញត្តិ

**មាត្រា១៤ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា១៥ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ១៣កើត ខែ មាឃ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៧ ខែ កុម្ភៈ ឆ្នាំ២០២២

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីសូមហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ប៉ាន សូរស័ក្តិ**

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១៥
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ